# សេចក្តីប្រកាសព័ត៌មាន

## CMA និង CGCC បង្កើតភាពជាដៃគូយុទ្ធសាស្ត្រដើម្បីពង្រឹងបរិយាបន្នហិរញ្ញវត្ថុ

**ភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥៖** សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និង សាជីវកម្មធានាឥណទានកម្ពុជា (CGCC) បានចុះហត្ថលេខាជាផ្លូវការលើអនុស្សរណៈនៃការយោគយល់គ្នា (MoU) ដើម្បីសហការលើការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពនៅទូទាំងប្រទេសកម្ពុជា។ ភាពជាដៃគូជាផ្លូវការនេះត្រូវបានប្រកាស នៅក្នុងសន្និបាតប្រចាំឆ្នាំរបស់ CGCC ស្តីពី «ការធ្វើនវានុវត្តន៍យន្តការធានាឥណទាន ដើម្បីគាំទ្រហិរញ្ញប្បទានបៃតង» ក្រោមអធិបតីភាព ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាល CGCC ។ ភាពជាដៃគូយុទ្ធសាស្ត្រនេះមានគោលបំណងជំរុញដល់ការអភិវឌ្ឍគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (BFIs) និងគាំទ្រសហគ្រាសធុនមីក្រូ ខ្នាតតូច និងមធ្យម (MSMEs) តាមរយៈការអភិវឌ្ឍសមត្ថភាព សេវាហិរញ្ញវត្ថុឌីជីថល និងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ។

តាមរយៈអនុស្សរណៈនៃការយោគយល់គ្នានេះ CMA និង CGCC នឹងធ្វើការរួមគ្នា ដើម្បីពង្រឹង និងអភិវឌ្ឍសមត្ថភាព MSMEs BFIs និងភាគីពាក់ព័ន្ធនានា ដោយ រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងធ្វើការសិក្សាស្រាវជ្រាវនានា ក្នុងគោលដៅលើកកំពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ជម្រុញសេវាហិញ្ញវត្ថុឌីជីថល និងការគាំទ្រគំនិតផ្តួចផ្តើមវិស័យបៃតងនៅកម្ពុជា ។ ស្ថាប័នទាំងពីរប្តេជ្ញាចិត្ត ក្នុងការប្រើធនធានដែលខ្លួនមានដើម្បីធានាឱ្យបាននូវការអនុវត្តប្រកបដោយជោគជ័យនូវគំនិតផ្តួចផ្តើម ផ្សេងៗក្នុងគោលបំណងជំរុញការរួមចំណែករបស់វិស័យហិរញ្ញវត្ថុដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ ប្រទេសកម្ពុជា។

ឧកញ៉ា ហួត អៀងតុង តំណាង សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាបានមានប្រសាសន៍ថា៖ «កិច្ចសហប្រតិបត្តិការនេះ គឺជាជំហ៊ានដ៏សំខាន់មួយក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ តាមរយៈការរួមបញ្ចូលគ្នាទាំងធនធាន និងជំនាញ យើងអាចបង្កើតនូវប្រព័ន្ធហិរញ្ញវត្ថុដ៏រឹងមាំ ដែលគាំទ្រការលូតលាស់នៃអាជីវកម្មធុនមីក្រូ តូច និងមធ្យម (MSMEs) ព្រមទាំងចូលរួមក្នុងការអភិវឌ្ឍនៅប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព»។

លោក ណូ លីដា អគ្គនាយក CGCC បានមានប្រសាសន៍ថា៖ «CGCC មានសេចក្តីសោមនស្សក្នុងការសហការជាមួយ CMA ដើម្បីពង្រឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងផ្តល់លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុកាន់តែប្រសើរឡើង។ CGCC និង CMA ក៏ដូចជាសមាជិករបស់ CMA នឹងមានឱកាសជាច្រើន ក្នុងការប្រើប្រាស់ការធានាឥណទាន ដើម្បីបង្កើនការផ្តល់ប្រាក់កម្ចីចាំបាច់ដល់អាជីវកម្ម ដែលមិនមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុនៅទូទាំងប្រទេស។ អនុស្សរណៈនៃការយោគយល់គ្នានេះ គឺជាសក្ខីភាពមួយ ចំពោះការប្តេជ្ញាចិត្តរួមគ្នារបស់យើងក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងនិរន្តរភាពនៅកម្ពុជា»។

អនុស្សរណៈនៃការយោគយល់គ្នានេះនឹងមានប្រសិទ្ធភាពរយៈពេលបីឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ហើយអនុស្សរណៈនេះមានចែងអំពីក្របខ័ណ្ឌសម្រាប់កិច្ចសហប្រតិបត្តិការទៅវិញទៅមកក្នុងការសម្រេចបានគោលបំណងរួមគ្នា។ ភាគីទាំងពីរប្តេជ្ញាធានានូវភាពសម្ងាត់នៃព័ត៌មានដែលបានចែករំលែក និងការអនុវត្តប្រកបដោយជោគជ័យនូវគំនិតផ្តួចផ្តើមដែលបានព្រមព្រៀងគ្នា។

**<u>សម្រាប់ព័ត៌មានបន្ថែមអំពីលទ្ធផលនៃសិក្ខាសាលា សូមទំនាក់ទំនង៖</u>**


សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA)
លោក កាំង តុងងី ប្រធាននាយកដ្ឋានទំនាក់ទំនង
អ៊ីមែល៖ hoc@cma-network.org
ទូរស័ព្ទ៖ +855 95 262 111

សាជីវកម្មធានាឥណទានកម្ពុជា (CGCC)
លោកស្រី ពិន ម៉ានីកា ប្រធានផ្នែកទីផ្សារ និងអភិវឌ្ឍន៍អាជីវកម្ម
អ៊ីមែល៖ manika.pin@cgcc.com.kh
ទូរស័ព្ទ៖ +855 23 722 123


-------- ចប់ ----

## អំពីសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA)

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា(សមក) គឺជាសមាគមវិជ្ជាជីវៈមិនរកប្រាក់ចំណេញ មានគោលដៅធានាអោយបានថាប្រជាជនកម្ពុជាគ្រប់រូបទទួលបាននូវសេវាហិរញ្ញវត្ថុផ្លូវការប្រកបដោយភាពសំបូរបែបទាន់ពេលវេលាតាមរយៈប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព។ យើងអាចសម្រេចគោលដៅនេះបានតាមរយៈការសម្របសម្រួលជាមួយប្រតិបត្តករ ព្រមទាំងពង្រឹងទំនាក់ទំនងជាមួយអាជ្ញាធរ ម្ចាស់ជំនួយ អ្នកផ្តល់ឥណទាន និងវិនិយោគិន។

## អំពីសាជីវកម្មធានាឥណទានកម្ពុជា (CGCC)

សាជីវកម្មធានាឥណទានកម្ពុជា (CGCC) គឺជាសហគ្រាសសាធារណៈ ស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានបេសកកម្មចម្បងផ្តល់ការធានាឥណទាន ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម៕